ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ១៥១/១០-០៤-២០១២

សាលដីកា

លេខ ១៦ក្រVI "រ"/៣១-០៧-២០១២

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៧-០៧-២០១២ ។

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**ក្រឡាបញ្ជី**

លោក ហម ហ៊ែល

**-ដើមចោទឈ្មោះ** [redacted] **លឹមប៉ូល** ភេទប្រុស មានទីលំនៅសព្វថ្ងៃផ្ទះលេខ១០៥ ផ្លូវជាតិលេខ១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

មានលោក [redacted] មេធាវីតំណាងដោយអាណត្តិ។

**-ចុងចម្លើយឈ្មោះ** [redacted]**ភុកច៉ាន់** ភេទប្រុស អាយុ៤៤ឆ្នាំ មុខរបរនាយកក្រុមហ៊ុនបេសតានហ្គាមេន LTD មានទីលំនៅផ្ទះលេខ២៣៣ មហាវិថីនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

មានលោក [redacted]ភា មេធាវីតំណាងដោយអាណត្តិ ។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖

-ទាមទារប្រាក់ឈ្នួលពីចុងចម្លើយចំនួន៤៧.០៥០$

-ទាមទារការប្រាក់តាមច្បាប់ចំនួន៥% ក្នុងមួយឆ្នាំ គិតចាប់ពីខែតុលា ឆ្នាំ២០០៨ រហូតដល់ចុងចម្លើយសងប្រាក់រួច

-ទាមទារជម្ងឺចិត្ត ថ្លៃខូចខាតផលប្រយោជន៍ ថ្លៃសេវាកម្មច្បាប់ និងការចំណាយសំរាប់រឿងក្តីសរុប៤០.០០០.០០០រ

-ការចំណាយលើប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗជាបន្ទុកភាគីចុងចម្លើយ។

-ស្នើសុំឲ្យមានការអនុវត្តជាបណ្តោះអាសន្នលើសាលក្រមនេះ។

## អង្គហេតុ និងចំណុចវិវាទ៖

តាមកិច្ចសន្យាជួលដី និងអាគារ ចុះថ្ងៃទី០៥-០១-២០០៤ ភាគីចុងចម្លើយបានជួលដី និងអាគារលេខ២៣៣ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ហៅ ឃ្លាំងបេ ពីខ្ញុំ ក្នុងតម្លៃ៦៥០០ដុល្លាអាមេរិកក្នុងមួយខែ។ការបង់ប្រាក់ឈ្នួលរបស់ចុងចម្លើយ ការប្រព្រឹត្តទៅជាធម្មតា។តែចាប់តាំងពីខែតុលា ឆ្នាំ២០០៨ រហូតដល់ខែមិថុនា ឆ្នាំ២០០៩ ភាគីចុងចម្លើយ មិនបានបង់ប្រាក់ឈ្នួលដែលជាកាតព្វកិច្ចរបស់ខ្លួនមកភាគីខ្ញុំបាទទេ។ក្រោយ មកនៅថ្ងៃទី១០-៦-២០០៩ ភាគីចុងចម្លើយបានធ្វើលិខិតទទួលស្គាល់ថា ពិតជានៅជំពាក់ប្រាក់ ខ្ញុំបាទចំនួន៥១.០៥០ដុល្លាអាមេរិក ប្រាកដមែន។ ក្រោយពីបានធ្វើលិខិតទទួលស្គាល់បំណុល រួចហើយ ភាគីចុងចម្លើយនៅមិនទាន់ធ្វើការទូទាត់ប្រាក់ឈ្នួលនេះមកភាគីខ្ញុំបាទទេ ទោះបីមាន ការទាមទារពីខ្ញុំបាទក៏ដោយ ទើបខ្ញុំបាទដាក់ពាក្យបណ្តឹងនេះមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីឲ្យសាលាដំបូងរាជធានីភ្នំពេញ ចេញសាលក្រមឲ្យភាគីចុងចម្លើយសងប្រាក់ឈ្នួលនេះ មកខ្ញុំបាទ។

## ការអះអាងរបស់ភាគីដើមចោទ៖

លោក[redacted] មេធាវីតំណាងដោយអាណត្តិឲ្យលោក[redacted] លឹមប៊ូល ថ្លែងហេតុ ថា:ពាក់ព័ន្ធនិងលិខិតចុះថ្ងៃទី០៩-៥-២០០៩ មានលិខិតពីរមួយលិខិតលោក[redacted]លឹមប៊ូល គាត់បានប្រគល់សិទ្ធិឲ្យលោកស្រី[redacted] ម៉ាលី ទទួលប្រាក់ឈ្នួលពីលោក[redacted] កុកង៉ាន់ អឺ ចឹង បានជាលោក[redacted] កុកង៉ាន់ ឲ្យលោកស្រី[redacted] ម៉ាលី លុបសិទ្ធិមួយចោលសិន លុប សិទ្ធិ ទទួលលុយលិខិតមួយទៀតចុះថ្ងៃទី០៩-៥-២០០៩មួយទៀតបើលិខិតដែលលោក មេធាវី បានលើកឡើងចុះថ្ងៃទី០៩-៥-២០០៩លិខិតនេះគឺគាត់ ធ្វើដោយខ្លួនឯងទេ។

លោក[redacted] មេធាវីតំណាងដោយអាណត្តិឲ្យលោក[redacted] លឹមប៊ូល ថ្លែងហេតុ ថា: ខ្ញុំសុំបដិសេធចោលការលើកឡើងរបស់មេធាវី[redacted] នៅថ្ងៃទី០៥-១-២០០៤ បាន ជួលទីតាំងឲ្យលោក[redacted] កុកង៉ាន់ដោយមានប្រាក់ឈ្នួលក្នុងមួយខែ៦៥០០ដុល្លាអាមេរិក ការបង់ប្រាក់របស់ចុងចម្លើយមានជំពាក់មានបង់រហូតដល់ខែ១០ឆ្នាំ២០០៦ ទើបភាគីចុង ចម្លើយឈប់បង់ ឲ្យកូនក្តីរបស់ខ្ញុំ។ទឹកប្រាក់ដែលគាត់ទទួលស្គាល់ជំពាក់៥១.០៥០ ដុល្លា អាមេរិក ហើយភាគីចុងចម្លើយបានទទួលស្គាល់ហើយ។ភាគីចុងចម្លើយបាន លើកឡើង អំពីការជួលទីតាំងដោយមានការដកសិទ្ធិដោយលោកស្រី[redacted] ម៉ាលី ជួលឲ្យលោ[redacted] លឹមប៊ូល ហើយលោក[redacted] លឹមប៊ូល បន្តជួលឲ្យលោក[redacted] កុកង៉ាន់ ។ខ្ញុំសុំជំរាបថា តាំងពី ចុះកិច្ចសន្យារហូតដល់បញ្ចប់កិច្ចសន្យា ពុំមានការរំខានការជួលនោះទេ ព្រោះថារោងចក្រ នោះ ប្រព្រឹត្តទៅធម្មតា។សរុបមករោងចក្រ ប្រព្រឹត្តទៅជាធម្មតា ពុំមានការរាំងស្ទះទេ ។ ចំណុចមួយទៀតរឿងប្រាក់កក់២៦.០០០ដុល្លាអាមេរិក ប្រាក់តចរន្តអគ្គិសនី៣៧.០០០ ដុល្លាអាមេរិក ក្នុងនេះលោកមេធាវីលើកឡើងថាសាលាដំបូងពុំមានភស្តុតាង ព្រោះនៅ ក្នុងកិច្ចសន្យាបានបញ្ជាក់យ៉ាងច្បាស់ព្រោះថាប្រការ៩នៃកិច្ចសន្យាចុះថ្ងៃទី០៥-១-២០០៤

បញ្ជាក់ច្បាស់ថា ប្រាក់កក់៤ខែ ត្រូវទូទាត់កាត់កងនៅពេលបញ្ចប់កិច្ចសន្យា ។ចំពោះប្រាក់តបណ្តាញអគ្គីសនីយោងមានកិច្ចសន្យាចុះថ្ងៃទី០៦-១-២០០៨គ្រង់ប្រកា៤បានបញ្ជាក់ហើយ។មុនចប់កិច្ចសន្យាមួយខែភាគីទាំងពីរបានទូទាត់ប្រាក់កក់ ប្រាក់អគ្គីសនី រួចរាល់អស់ហើយ ក្រោយពីការទូទាត់សរុបចប់សព្វគ្រប់ហើយគឺភាគីតាន់ កុកង៉ាន់ ពិតជានៅជំពាក់កូនក្តីខ្ញុំចំនួន៥១.០៥០ដុល្លាអាមេរិក ប្រាកដមែន។ហើយគាត់ក៏បានធ្វើលិខិតមួយទទួលស្គាល់បំណុល។នៅសាលាដំបូងយើងទាមទារ៥១.០៥០ដុល្លាអាមេរិក ប៉ុន្តែនៅសល់៤៧.០៥០ដុល្លាអាមេរិក វិញ ពេលដែលគាត់ធ្វើលិខិតទទួលស្គាល់បំណុលហើយ គាត់បានសង២.០០០ដុល្លាអាមេរិក ចំនួនពីរលើកទៀត។នេះបញ្ជាក់ថា គាត់ទទួលស្គាល់បំណុលហើយ។ចំពោះប្រាក់ជម្ងឺចិត្តកូនក្តីខ្ញុំទាមទារ៥០លានរៀលហើយតុលាការសម្រេចឲ្យចំនួន៣៥លានរៀល រឿងនេះអូសបន្លាយជាច្រើនឆ្នាំមកហើយ ។ខ្ញុំសុំតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ថ្លែងហេតុថា:ខ្ញុំសុំបញ្ជាក់បន្ថែមដែលសហភាគាបានបញ្ជាក់រួចហើយ ខ្ញុំសុំបញ្ជាក់ពីប្រការ៩ ចំពោះប្រាក់ឈ្នួល ប្រាក់កក់ ប្រាក់តបណ្តាញអគ្គីសនីព្រោះកិច្ចសន្យាបានបញ្ជាក់ហើយ ។ ហើយចុងចម្លើយបានចុះកិច្ចសន្យាមួយទៀតទទួលស្គាល់បំណុលរបស់ខ្លួន។បើសិនជាកូនក្តីរបស់ខ្ញុំនៅជំពាក់គាត់ រឿងអីពេលធ្វើកិច្ចសន្យានេះគាត់មិនបញ្ជាក់ ថាកូនក្តីខ្ញុំជំពាក់ប៉ុន្មាន? នៅសល់ប៉ុន្មាន?។សុំតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ។

**<u>ការអះអាងរបស់ភាគីចុងចម្លើយ</u>** ៖

លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយធ្វើសេចក្តីថ្លែងហេតុថា: ពាក្យសុំផ្អាកនីតិវិធីនៃបណ្តឹងមូលហេតុដោយសារលោក [redacted] លឹមប៊ូល យោងតាមលិខិតនេះ លោក [redacted] លឹមប៊ូល អស់សិទ្ធិតាំងពីឆ្នាំ២០០៦មក លោក [redacted] លឹមប៊ូល មិនបានផ្អាកតាមនេះទេ បែរជាឲ្យកូនក្តីខ្ញុំចុះហត្ថលេខាជំពាក់ប្រាក់ឈ្នួលទីតាំងដីចុះថ្ងៃទី១០-៦-២០០៩ ដោយលោក [redacted] លឹមប៊ូល ខ្លួនឯងអស់សិទ្ធិហើយ ដូចនេះកូនក្តីរបស់ខ្ញុំមិនត្រូវសងទៅលោក [redacted] លឹមប៊ូល ទេ។តាមលិខិតបញ្ជាក់របស់លោកស្រី [redacted] ម៉ាលី ដូច្នេះគាត់ត្រូវសងទៅលោកស្រី [redacted] ម៉ាលី ទៅវិញ។តុលាការសាលាដំបូងសម្រេចទៅលើលិខិតទទួលស្គាល់បំណុលនេះ ហើយបើរឿងនេះទៅដល់តុលាការកំពូលហើយឲ្យកូនក្តីខ្ញុំសងគឺសងបំណុលខុសភាគី ហើយព្រោះភាគីដែលមានសិទ្ធិគឺភាគី [redacted] ម៉ាលី វិញ។សុំតុលាការពិចរណា ទៅតាមការស្នើសុំ ហើយកូនក្តីរបស់ខ្ញុំបានស្នើសុំលុបលិខិតនេះចោលព្រោះដោយការភន្តច្រឡំ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យលោក [redacted] កុកង៉ាន់ ថ្លែង ហេតុថា: មូលហេតុដែលកូនក្តីរបស់ខ្ញុំប្តឹងឧទ្ធរណ៍ និងសាលក្រមនេះ ដោយមានមូលហេតុដូចតទៅ: ទី១កូនក្តីរបស់ខ្ញុំ បានចុះកិច្ចសន្យាជួលទីតាំងបើកជាសហគ្រាសកាត់ដេរ តាមប្រវត្ត



Scanned with CamScanner

ដែលកូនក្ដីបានប្រាប់ខ្ញុំគឺទីតាំងនេះមានទំនាស់ជាច្រើនមកហើយ គឺត្រូវបានរដ្ឋដកហូតសិទ្ធិពីលោកស្រី[redacted] ម៉ាលី។ លោកស្រី[redacted] ម៉ាលី ជូលឲ្យលោក[redacted] លឹមប៉ូល ហើយលោក[redacted] លឹមប៉ូល ជូលទីតាំងនេះឲ្យកូនក្ដីរបស់ខ្ញុំ យើងមានឯកសារមួយចំនួនដែលពាក់ពន្ធ័ទៅនឹងចំណុចនេះ រដ្ឋបានដកពីលោកស្រី[redacted] ម៉ាលី តាំងពីឆ្នាំ២០០៣លោក[redacted] ប៉ូល ជូលពីលោកស្រី[redacted] ម៉ាលី ដូច្នេះកិច្ចសន្យាជូលក៏មានបញ្ហាដែរ។ ប៉ុន្តែខ្ញុំសុំលើកអង្គហេតុដែលកូនក្ដីរបស់ខ្ញុំបានប្ដឹងពាក់ពន្ធ័នឹងឈ្មោះ[redacted] លឹមប៉ូល បានចុះកិច្ចសន្យា ជាមួយកូនក្ដីរបស់ខ្ញុំថ្ងៃទី០៥-០១-២០០៤ គឺមានចំណុចពីរ ដែលកូនក្ដីខ្ញុំសន្យាជាមួយលោក[redacted]លឹមប៉ូល ទី១ពាក់ពន្ធ័ទៅនឹងប្រាក់កក់ ចំនួន២៦០០០$ ហើយភាគីទាំងពីរសន្យាថានឹងទូទាត់គ្នានៅពេល៤ខែចុងក្រោយនៃការបញ្ចប់កិច្ចសន្យាចំណុចនេះមានសរសេរច្បាស់ នៅក្នុងកិច្ចសន្យា។អីចឹងនៅពេលកិច្ចសន្យាត្រូវបានបញ្ចប់ភាគីទាំងពីរ ភាគីលោក[redacted] លឹមប៉ូល មិនបានទូទាត់បាក់នេះ មកឲ្យកូនក្ដីរបស់ខ្លួន ទីពីរពាក់ពន្ធ័ការតចរន្តអគ្គីសនី នៅពេលធ្វើកិច្ចសន្យាភាគីសុំឲ្យលោក[redacted] លឹមប៉ូល តចរន្តអគ្គីសនី ។ពេលនោះលោក[redacted] លឹមប៉ូល គាត់ថាអត់ទាន់មានប្រាក់តចរន្តអគ្គីសនីដើម្បីដំណើរការសហគ្រាសរបស់គាត់ទេ អីចឹងគាត់ឲ្យកូនក្ដីខ្ញុំចេញលុយមុនលុយតចរន្តអគ្គីសនីអស់៣៧០០០ ដុល្លាអាមេរិក ហើយគាត់បានធ្វើកិច្ចសន្យាមួយទៀតជាមួយលោកឡុ លឹមប៉ូល ស្ដីពីការផ្ទេរចរន្តអគ្គីសនីហើយ នៅក្នុងកិច្ចសន្យាផ្ទេរចរន្តអគ្គីសនីនេះនៅក្នុងប្រការ៥កិច្ចសន្យានេះមានជាក់ភស្តុតាងនៅក្នុងសំណុំរឿង ចំណុចនេះលោក[redacted] លឹមប៉ូល មិនទាន់អនុវត្តដែរ។ ហើយនៅក្នុងឆ្នាំ២០០៩ លោក [redacted]លឹមប៉ូល បានទារប្រាក់ឈ្នួលទីតាំងពីកូនក្ដីខ្ញុំនៅឆ្នាំ២០០៩ពេលកូនក្ដីខ្ញុំចង់បន្តកិច្ចសន្យាទៀត តែលោក[redacted] លឹមប៉ូល មិនចង់បន្តទេព្រោះដីនេះរដ្ឋដកពីលោកស្រី[redacted] ម៉ាលី អីចឹងលោកស្រី[redacted] ម៉ាលី អស់សិទ្ធិ ហើយគាត់ជូលពីលោកស្រី[redacted] ម៉ាលី មកគាត់ក៏អស់សិទ្ធិ អីចឹងហើយបានជាលោក [redacted] លឹមប៉ូល ឲ្យកូនក្ដីខ្ញុំផ្ដិតមេដៃទទួលស្គាល់បំណុលហ្នឹងបំណុលឈ្នួលទីតាំងដី ។កិច្ចសន្យាចុះថ្ងៃទី១០-៦-២០០៩ នៅក្នុងចំណុចនេះសរសេរខ្លីទេខ្ញុំសុំអានបន្តិច។នៅពេលសវនាការសាលាដំបូងខ្ញុំបានលើកដែរ អត់មានចំណុចណាមួយពាក់ពន្ធ័ទៅនឹងការទូទាត់ទេ ហើយនៅ ក្នុងនោះលោកចៅក្រមបានយល់ឃើញនៅក្នុងសាលក្រម ហើយការយល់ឃើញនោះខ្ញុំថា មិនត្រឹមត្រូវដោយគាត់យល់ឃើញផ្ទាល់ខ្លួនគាត់ពុំបានយកភស្តុតាងមកយល់ឃើញទេគឺ ចំណុចវិវាទតើមានការទូទាត់ប្រាក់កក់ និងប្រាក់តចរន្តអគ្គីសនីហើយឬនៅ?។ខ្ញុំសុំអាន ចំណុចយល់ឃើញនៅក្នុងសាលក្រមសាលាដំបូង។ជាគោលការណ៍ច្បាប់តុលាការត្រូវទទួលស្គាល់អង្គហេតុ និងភស្តុតាង។ហើយរហូតដល់ពេលនេះលោកឡុ លឹមប៉ូល មិនទាន់មានភស្តុតាងណាមួយដាក់មកតុលាការដើម្បីបញ្ជាក់ថា ខ្លួនបានទូទាត់ប្រាក់កក់និងប្រាក់ចរន្តអគ្គីសនីឲ្យកូនក្ដីខ្លួនទេ។ ការសម្រេចឲ្យកូនក្ដីខ្ញុំសង៣៥លានរៀលការសម្រេចនេះភាគីដើមចោទ អត់មានភស្តុតាងអ្វីទាំងអស់ ។ម្យ៉ាងទៀត កូនក្ដីខ្ញុំបានប្ដឹងតប ហើយ

តុលាការមិនបាន ពិចារណា។ខ្ញុំសុំលុបចោលសាលក្រមរបស់សាលាដំបូងចោល សុំធ្វើការទូទាត់បំណុលឡើងវិញ លោកឡូ លឹមប៉ូល ត្រូវជំពាក់កូនក្តីខ្ញុំដូចមានពាក្យបណ្តឹងនៅក្នុងសំណុំរឿង។ពាក់ពន្ធ័និង ការលើកឡើងថាពិតជាមានការទូទាត់មែននោះ ជាការយល់ឃើញផ្ទាល់ខ្លួនគាត់ អត់មានអ្វី បញ្ជាក់ទេ ហើយគាត់ថាការទូទាត់បំណុលនេះគឺការទូទាត់ចុងក្រោយ ខ្ញុំសុំសួរថាពាក្យណាថា ចុងក្រោយវាអត់មាន សុំលោកចៅក្រមមេត្តាពិនិត្យឡើងវិញ។គាត់ថាទូទាត់នៅ៤ខែចុងក្រោយនៅក្នុងនោះគឺខែ១០ខែ១១ខែ១២អីចឹងគឺប្រាក់ឈ្នួលទីតាំងមិនមែនប្រាក់កក់ទេ ដូច្នេះវាសុីសង្វាក់គ្នាទៅនឹងអ្វីដែលកូនក្តីរបស់ខ្ញុំបានអះអាងថាមិនទាន់បានទូទាត់នៅឡើយ។

**សំអាងហេតុ ៖**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-១-២០១២ របស់ឈ្មោះ[redacted]កុកង៉ាន់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ៥៧"ណ"ចុះថ្ងៃទី២១-៩-២០១១ ត្រង់ចំណុចទី១វាក្យខណ្ឌទី១, ចំណុចទី២ និងទី៣របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់យោងមាត្រា២៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន។

២-មេធាវីចុងចម្លើយបានថ្លែងហេតុថា សុំពិនិត្យភស្តុតាងគឺលិខិតបញ្ជាក់លេខ៥៤/០៦ ចុះថ្ងៃទី០៩-៥-២០០៦របស់ក្រុមហ៊ុន[redacted] ម៉ាលី អាហារ័ណនីហារ័ណដោយមានន័យបញ្ជាក់ថា លោក[redacted]លឹមប៉ូល ត្រូវបានលោកជំទាវ[redacted]ម៉ាលី ដកសិទ្ធិជួលឃ្លាំងBតាំងពីថ្ងៃ០៩-៥-២០០៦ ដូច្នេះលោក[redacted] លឹម៉ូល អស់សិទ្ធិលើកិច្ចសន្យាជួលឃ្លាំងB ឲ្យកូនក្តីខ្លួនតាំងពីថ្ងៃ០៩-៥-២០០៦មក។ ប៉ុន្តែមេធាវីដើមចោទបានថ្លែងហេតុថាលិខិតបញ្ជាក់លេខ៥៥៤/០៦ចុះថ្ងៃទី០៩-០៦-២០០៦ដែលមេធាវីចុងចម្លើយលើកឡើងនេះ គឺគ្រាន់តែជាលិខិតបញ្ជាក់ផ្ទៃក្នុងរវាងកូនក្តីខ្លួន និងលោកជំទាវ[redacted] ម៉ាលី ដើម្បីឲ្យលោកជំទាវ[redacted] ម៉ាលី បើកយកប្រាក់ថ្លៃឈ្នួលទីតាំងឃ្លាំងBតាមកិច្ចសន្យាជួលចុះថ្ងៃទី០៥-១-២០០៨រវាងកូនក្តីខ្លួននិងចុងចម្លើយតែប៉ុណ្ណោះ ដូចមានលិខិតផ្ទេរសិទ្ធិលេខ៥៣/០៦ចុះថ្ងៃទី០៩-៥-២០០៦បញ្ជាក់ស្រាប់។ម៉្យាងទៀត កូនក្តីខ្លួនក៏មិនដែលធ្វើអ្វីឲ្យរំខានដល់ការជួលរបស់ចុងចម្លើយ ដោយសារតែលិខិតផ្ទេរសិទ្ធិលេខ៥៣/០៦ និងលិខិតបញ្ជាក់លេខ៥៥៤/០៦ចុះថ្ងៃទី០៩-៥-២០០៦រវាងកូនក្តីខ្លួននិងលោកជំទាវ[redacted] ម៉ាលី ដែរ។ចំណុចនេះសាលាឧទ្ធរណ៍យល់ថា សេចក្តីថ្លែងហេតុរបស់មេធាវីដើមចោទ មានហេតុផលបញ្ជាក់ត្រឹមត្រូវ ព្រោះថាលិខិតផ្ទេរសិទ្ធិលេខ៥៣/០៦និងលិខិតបញ្ជាក់លេខ៥៥៤/០៦ ចុះថ្ងៃទី០៩-៥-២០០៦ គឺគ្រាន់តែជាលិខិតបញ្ជាក់ផ្ទៃក្នុងរវាងដើមចោទនិងលោកជំទាវ[redacted] ម៉ាលី ប៉ុណ្ណោះ មិនមានអ្វីប៉ះពាល់ដល់កិច្ចសន្យាជួលឃ្លាំងB ចុះថ្ងៃទី០៥-១-២០០៨រវាងដើមចោទ និងចុងចម្លើយឡើយ។

៣-ចុងចម្លើយបានទទួលស្គាល់នៅជំពាក់ថ្លៃឈ្នួលទីតាំងឃ្លាំងB របស់ដើមចោទ ចំនួន៥១.០៥០$ តាមលិខិតចុះថ្ងៃទី១០-៦-២០០៩ ។ចំណុចនេះសាលាឧទ្ធរណ៍យល់ថា ពិតជាបានទូទាត់ថ្លៃតបណ្តាញចរន្តអគ្គិសនីដែលមានទឹកប្រាក់សរុប៣៧.០០០$ រួចហើយ ព្រោះត្រូវទូទាត់មួយខែមុនបញ្ចប់កិច្ចសន្យាជួលឃ្លាំងថ្ងៃ០៥-១-២០០៨ និងប្រាក់កក់៤ខែ ត្រូវកាត់កងក្នុងរយៈពេល៤ខែចុងក្រោយ នៃការបញ្ចប់កិច្ចសន្យាជួល ហើយចុងចម្លើយ បានទទួលស្គាល់បំណុល ក្រោយបញ្ចប់កិច្ចសន្យាជួល រហូតរយៈពេលជាជាងប្រាំខែឯណោះ ។ ដូច្នេះគ្មានហេតុផលណាមួយដែលថាដើមចោទមិនទាន់បានទូទាត់ថ្លៃតបណ្តាញអគ្គិសនី និងប្រាក់កក់៤ខែក្រោយបញ្ចប់កិច្ចសន្យាជាមួយចុងចម្លើយ មុនពេលចុងចម្លើយទទួលស្គាល់ បំណុល តាមលិខិតចុះថ្ងៃទី១០-៦-២០០៩នោះឡើយ។

៤-មេធាវីចុងចម្លើយបានអះអាងថា បើដើមចោទទូទាត់ថ្លៃតបណ្តាញអគ្គិសនីឲ្យ ក្រុមហ៊ុនខ្លួនហេតុអ្វីបានជាបណ្តាញអគ្គិសនីនោះនៅតែមានឈ្មោះក្រុមហ៊ុនខ្លួនដដែល។ ចំណុច នេះ សាលាឧទ្ធរណ៍យល់ឃើញថាៈពុំមានលក្ខណៈសមហេតុផលឡើយ ព្រោះថាចុង ចម្លើយជាអ្នកប្រើប្រាស់បណ្តាញអគ្គិសនី ដើម្បីបំរើអាជីវកម្មរបស់ខ្លួនបន្តទៀតមិនមែន ដើមចោទជាអ្នកប្រើប្រាស់ទេ។ ឯការទូទាត់គឺទូទាត់តែសាច់ប្រាក់ប៉ុណ្ណោះ។

៥-មេធាវីចុងចម្លើយសុំឲ្យសាលាឧទ្ធរណ៍ពិចារណាពីជម្ងឺចិត្តនោះ សាលាឧទ្ធរណ៍ យល់ឃើញថា ជម្ងឺចិត្តនោះមានលក្ខណៈ សមរម្យហើយ។

៦-សាលក្រមរដ្ឋប្បវេណីលេខ៥៧"ណ"ចុះថ្ងៃទី២១-៩-២០១១ របស់សាលាដំបូង រាជធានីភ្នំពេញ ដែលបានសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដូច មានសំអាងហេតុបញ្ជាក់ស្រាប់ ដែលគប្បីសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ។

**ហេតុដូច្នេះ ទនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-១-២០១២ របស់ឈ្មោះ [redacted] កុកង៉ាន់ ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះអង្គច្បាប់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៥៧"ណ"ចុះថ្ងៃទី២១-៩-២០១១ របស់សាលា ដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី១ វាក្យខណ្ឌទី១,ចំណុចទី២និងទី៣ ទុកជាបានការ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted] កុកង៉ាន់។

សាលាដីកានេះប្រកាសជាសាធារណៈថ្ងៃទី៣១-៧-២០១២។

ទុកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា [redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

...ត្រឹមត្រូវតាមច្បាប់ដើម ។

[redacted]

[redacted]